ឆ្នាំទី2៖ លេខ 8 / ខែឧសភា ឆ្នាំ2026

EQUITY ENGAGEMENT & PARTNERSHIPS
LONG BEACH UNIFIED SCHOOL DISTRICT

ព្រឹត្តិបត្រព័ត៌មាន

@lbusdengage lbschools.net/engage LONG BEACH UNIFIED • SCHOOL • DISTRICT



ព្រឹត្តិការណ៍ដ៏សំខាន់មួយ

យើងខ្ញុំ ពិតជារំភើបចិត្ត ក្នុងការបង្ហាញ អំពីសិស្សដែលបំផុសគំនិតជាងគេ ក្នុងឆ្នាំ2026 របស់មន្ទីរអប់រំ LBUSD! វាជាការរំលឹកដ៏មានឥទ្ធិពលមួយ អំពីដំណើរដ៏បំផុសគំនិត ដោយផ្តល់ឱ្យសិស្សដ៏ឆ្នើមរបស់យើងនូវការទទួលស្គាល់ និងពង្រឹងតួនាទីរបស់ពួកគាត់ ក្នុងការធ្វើជាគំរូល្អ នៅក្នុងសហគមន៍មន្ទីរអប់រំ LBUSD នេះ។

នៅក្នុងការចេញផ្សាយនេះ

- **C.A.F.E. - ចំណុចលេចធ្លោជាច្រើន មកពីបទង្ហាញរបស់មន្ទីរអប់រំ ស្តីពីការបីបាច់ចិញ្ចឹមកូនរបស់អ្នក ដោយមនុស្សពេញវ័យ (ទំព័រ 3)**
- **ចំណុចលេចធ្លោជាច្រើន មកពី ពិធីបុណ្យប្រារព្ធមរតកវប្បធម៌ជនជាតិអាស៊ី និងជនជាតិពីកោះតំបន់ប៉ាស៊ីហ្វិក (AAPI) (ទំព័រ 4)**
- **ព័ត៌មានថ្មីៗ អំពីថវិកា ប្រចាំខែឧសភា (ទំព័រ 4)**
- **ចំណុចលេចធ្លោជាច្រើន របស់ការិយាល័យ EEP នៅដំណាច់ឆ្នាំនេះ (ទំព័រ 2)**
- **ការកែប្រែថ្មីៗ អំពីផែនការគ្រប់គ្រង និងគណនេយ្យភាព ប្រចាំមូលដ្ឋាន (LCAP) (ទំព័រ 4)**



រួមជាមួយគ្នា គឺយើងកំពុងកសាងអនាគតកាន់តែប្រសើរមួយ ទាំងនៅក្នុង និងជាមួយសហគមន៍របស់យើង!

ខណៈពេលដែលយើងឈានចូលដល់ដំណាច់ឆ្នាំនេះ ការិយាល័យសមធម៌ ការចូលរួម និងភាពជាដៃគូ (EEP) បន្តប្រារព្ធអបអរចំពោះឥទ្ធិពលនៃការភ្ជាប់ទំនាក់ទំនង និងកិច្ចសហការរបស់សហគមន៍នៅទូទាំងមន្ទីរអប់រំឡុងបីចទាំងមូល។ នៅខែនេះ យើងពិតជាមានមោទនភាពក្នុងការលើកបង្ហាញនូវឱកាសជាច្រើន ដែលនាំគ្រួសារ សិស្សានុសិស្ស បុគ្គលិក និងដៃគូសហគមន៍នានា មកជួបជុំគ្នា តាមរបៀបដ៏ពោរពេញដោយអត្ថន័យជាច្រើន ខណៈពេលដែលកំពុងបន្តលើកម្ពស់មតិយោបល់ និងបទពិសោធន៍ទាំងឡាយ ដែលពង្រឹងដល់សាលារៀន និងសហគមន៍របស់មន្ទីរអប់រំនៃយើង ឱ្យកាន់តែរឹងមាំជាបន្តទៀត។

នៅក្នុងការបោះពុម្ពផ្សាយលើកនេះ យើងខ្ញុំធ្វើការអបអរចំពោះការបញ្ចប់វគ្គសិក្ខាសាលា ស្តីពីការចិញ្ចឹមបីបាច់កូន និងការប្តេជ្ញាចិត្តរបស់គ្រួសារ ដែលបានបញ្ចប់កម្មវិធីសិក្ខាសាលានេះ ដោយទទួលស្គាល់នូវសេចក្តីរីករាយ និងមោទនភាពវប្បធម៌ ដែលបានចែករំលែកគ្នាក្នុងពិធីបុណ្យ AAPI ហើយនិងអញ្ជើញដៃគូធ្វើការអប់រំរបស់យើង ឱ្យចូលរួមក្នុងអំឡុងពេលធ្វើការពិនិត្យមើល និងផ្តល់មតិកែលម្អជាសាធារណៈ ចំពោះសេចក្តីព្រាងផែនការ LCAP ចាប់ពី ថ្ងៃទី22 ខែឧសភា ដល់ ថ្ងៃទី9 ខែមិថុនា។ យើងខ្ញុំ នៅតែថ្លែងអំណរគុណចំពោះកិច្ចសហការជាហូរហែរ និងអនុសាសន៍ទាំងឡាយ ដែលបានចែករំលែក តាមរយៈកិច្ចប្រឹងប្រែងចូលរួម ដែលជួយដឹកនាំ និងផ្តល់ព័ត៌មានដល់កិច្ចការដែលយើងធ្វើ ក្នុងការគាំទ្រដល់សិស្សានុសិស្ស និងគ្រួសារនានា នៅទូទាំងមន្ទីរអប់រំ LBUSD នេះ។

Dr. Lucy Salazar



រូបថតបង្ហាញពីសកម្មភាពល្អៗ របស់ការិយាល័យ EEP





កិច្ចការនៅក្នុងខែនេះ លើកបង្ហាញនូវវិធីជាច្រើន ដែលការិយាល័យសមធម៌ ការចូលរួម និងភាពជាដៃគូ (EEP) សហការជាមួយសិស្សានុសិស្ស គ្រួសារ និងអង្គការនៅតាមសហគមន៍ ដើម្បីលើកកម្ពស់មតិយោបល់របស់សហគមន៍ ពង្រឹងចំណងទំនាក់ទំនង និងជួយគាំទ្រដល់ភាពជោគជ័យរបស់សិស្សានុសិស្ស តាមរយៈការអនុវត្តដែលឆ្លើយតបនឹងវប្បធម៌ ហើយនិងឱកាសរួមគ្នាក្នុងភាពជាអ្នកដឹកនាំ។ តាមរយៈសិក្ខាសាលាជាច្រើនសម្រាប់គ្រួសារ ពិធីអបអរនៅតាមសហគមន៍ កិច្ចប្រឹងប្រែងចូលរួមធ្វើផែនការ LCAP គណៈកម្មការប្រឹក្សាណែនាំនានា គំនិតផ្តួចផ្តើមនៃការបង្កើតកិច្ចសហការដៃគូ ហើយនិងគំនិតផ្តួចផ្តើមក្នុងការផ្តល់សេវាអតិថិជន គឺការិយាល័យ EEP បន្តបង្កើតនូវកន្លែងដ៏រាក់ទាក់ស្វាគមន៍ ដែលគ្រួសារទាំងអស់យល់ថាទទួលបានដំណឹង គុណម្លៃ និងការពង្រឹងសមត្ថភាព ដើម្បីចូលរួមក្នុងការសិក្សាអប់រំរបស់កូនពួកគាត់បាន។














ក្រុមចូលរួមចំណែកជាមាតាបិតា
សូមរង់ចាំទទួលកាលវិភាគកម្មវិធី សម្រាប់ឆ្នាំសិក្សា 26-27







ក្រុមមាតាបិតានានា

បន្ថែមពីលើកម្មវិធី CAFE នេះទៀត គឺក្រុមគ្រួសារអាចចូលរួមក្នុងក្រុមមាតាបិតាផ្សេងៗទៀតរបស់មន្ទីរអប់រំបាន ដែលកសាងជំនាញ និងបទពិសោធន៍ដែលពួកគេនាំមក ខណៈពេលដែលផ្តល់ឱកាសដ៏មានអត្ថន័យ សម្រាប់ភាពជាអ្នកដឹកនាំ ភាពរីកចម្រើន និងការសិក្សា។ ក្រុមទាំងនេះ នាំមាតាបិតានានាមកជួបជុំគ្នា ដើម្បីស្វែងយល់អំពីគំនិតផ្តួចផ្តើមរបស់មន្ទីរអប់រំ ចែករំលែកមតិយោបល់ និងសហការគ្នារិះរកមធ្យោបាយដើម្បីជួយជ្រោមជ្រែងដល់សិស្សទាំងអស់បាន។ តាមរយៈការចូលរួម គឺមាតាបិតាមិនត្រឹមតែពង្រឹងជំនាញភាពជាអ្នកដឹកនាំរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយបង្កើតអនាគតនៃសាលារៀន និងសហគមន៍របស់យើងផងដែរ។

DISTRICT COMMUNITY ADVISORY COMMITTEE
LONG BEACH UNIFIED SCHOOL DISTRICT

គណៈកម្មការប្រឹក្សាសហគមន៍ប្រចាំមន្ទីរអប់រំ (DCAC) គឺមានសមាសភាគជាតំណាងមាតាបិតា មកពីសាលារបស់មន្ទីរអប់រំ LBUSD ទាំងឡាយ ដែលឧបត្ថម្ភដោយមូលនិធិសហព័ន្ធ Title 1។ មាតាបិតា ត្រូវបានផ្តល់ឱកាសឱ្យចូលរួមពាក់ព័ន្ធ និងទទួលដំណឹងអំពីការសិក្សារបស់កូនពួកគាត់។ មាតាបិតា ត្រូវបានលើកទឹកចិត្តឱ្យចែករំលែកព័ត៌មានអំពីកិច្ចប្រជុំ ជាមួយមាតាបិតាផ្សេងៗទៀត នៅសាលារបស់ពួកគេ។ **ការប្រជុំលើកក្រោយ៖ ថ្ងៃព្រហស្បតិ៍ ទី4 ខែមិថុនា នៅវិទ្យាល័យ Browning – ម៉ោង 5:30ល្ងាច**

DISTRICT ENGLISH LEARNER ADVISORY COMMITTEE
LONG BEACH UNIFIED SCHOOL DISTRICT

គណៈកម្មការប្រឹក្សាសិស្សរៀនភាសាអង់គ្លេសប្រចាំមន្ទីរអប់រំ (DELAC) គឺជាវិធីសម្រាប់មាតាបិតា អាចចូលរួមចំណែកក្នុងការអប់រំរបស់កូនពួកគាត់ នៅកម្រិតមន្ទីរអប់រំបាន។ ជារៀងរាល់ខែ មានតំណាងគណៈកម្មការ DELAC មាតាបិតា ថ្នាក់ដឹកនាំមន្ទីរអប់រំ និងសមាជិកសហគមន៍ ចូលរួមក្នុងការប្រជុំទាំងនេះ។ **ការប្រជុំលើកក្រោយ៖ ថ្ងៃអង្គារ ទី2 ខែមិថុនា នៅវិទ្យាល័យ Browning – ម៉ោង 9:30ព្រឹក**







SANKOFA PARENT VILLAGE
LONG BEACH UNIFIED SCHOOL DISTRICT

ភូមិមាតាបិតាសាំងកូហ្វា (SPV) ជាសហគមន៍មើលថែ និងជួយផ្គត់ផ្គង់សម្រាប់មាតាបិតា និងអ្នកមើលថែរបស់កុមារអាមេរិកខ្មៅ។ មន្ទីរអប់រំ LBUSD ប្តេជ្ញាផ្តោតចិត្តទុកដាក់លើតម្រូវការពិសេសរបស់សមាជិកសហគមន៍របស់យើង និងចូលរួមតាមរបៀបដែលលើកកម្ពស់ដល់អត្តសញ្ញាណវប្បធម៌របស់ពួកគេ។ **ការប្រជុំលើកក្រោយ៖ ថ្ងៃច័ន្ទ ទី8 ខែមិថុនា នៅមជ្ឈមណ្ឌលធនធានគ្រូបង្រៀន (TRC) – ម៉ោង 5:30ល្ងាច**

EDUCATIONAL OPPORTUNITIES for NATIVE AMERICANS and NATIVE ALASKANS
LONG BEACH UNIFIED SCHOOL DISTRICT


កម្មវិធីរបស់យើង ត្រូវបានរបង្កើតឡើង ដើម្បីធានាថា សិស្សជនជាតិដើមអាមេរិក (AI)/ និងជនជាតិដើមអាឡាស្កា (AN) នៅក្នុងមន្ទីរអប់រំឡុងប៊ីច មានឱកាសស្មើភាពគ្នា ក្នុងការទទួលបានការអប់រំ។ មាតាបិតា អាណាព្យាបាល បុគ្គលិកមន្ទីរ និងដៃគូនៅតាមសហគមន៍ ចូលរួមក្នុងការរៀបចំកម្មវិធីសិក្សា និងព្រឹត្តិការណ៍ផ្សេងៗ។ **សូមរង់ចាំទទួលដំណឹង អំពីកាលវិភាគ ឆ្នាំ 2026-27 ។**

សិក្ខាលាសម្រាប់មាតាបិតា
ដើម្បីរៀនសូត្រ រីកចម្រើន និងពង្រឹងសមត្ថភាព រួមជាមួយគ្នា៖ នៅក្នុង និង ជាមួយ សហគមន៍

C.A.F.E.
ការចូលរួមសំរាប់សហគមន៍ និង គ្រួសារ



សិក្ខាសាលា C.A.F.E. នៅខែមេសារបស់យើង បានរៀបចំធ្វើបទបង្ហាញ ស្តីពីការចិញ្ចឹមបីបាច់កូនដែលវិវត្តចូលវ័យជំទង់



សូមចូលរួមជាមួយយើងខ្ញុំ ក្នុងសិក្ខាសាលា C.A.F.E. លើកចុងក្រោយរបស់យើង ក្នុងឆ្នាំនេះ នៅថ្ងៃសុក្រ ទី29 ខែឧសភា ឆ្នាំ2026 នៅម៉ោង 9:30ព្រឹក





LONG BEACH UNIFIED • SCHOOL • DISTRICT
Excellence and Equity



បង្ហាញជូន

ខួបឆ្នាំទី2

ពិធីបុណ្យប្រារព្ធ
មរតកវប្បធម៌

ជនជាតិអាស៊ី និងជនជាតិ
កោះតំបន់ប៉ាស៊ីហ្វិក (AAPI)










ពិធីទទួលសញ្ញាបត្របញ្ចប់វគ្គសិក្ខាសាលា ស្តីពី ដៃគូក្នុងការចិញ្ចឹមបីបាច់កូន

🎉សូមធ្វើការអបអរសាទរ ចំពោះគ្រួសាររបស់មន្ទីរអប់រំយើង ដែលបានបញ្ចប់វគ្គសិក្សាកម្មវិធី អំពីការចិញ្ចឹមបីបាច់កូន! កម្មវិធីនេះ ពង្រឹងសមត្ថភាពមាតាបិតាជាច្រើន ក្នុងនាមជាអ្នកដឹកនាំនៅក្នុងផ្ទះរបស់ពួកគាត់។ សិក្ខាសាលាជាច្រើន ត្រូវបានឆ្នៃបង្កើតឡើង ដើម្បីផ្តល់ឱ្យមាតាបិតាទាំងឡាយ នូវវិធីសាស្ត្រដែលអាចប្រើបាន ដើម្បីជួយកូនៗរបស់ខ្លួន ក្នុងការសិក្សា សតិអារម្មណ៍ និងការប្រាស្រ័យទាក់ទងសង្គម ខណៈពេលដែលលើកកម្ពស់ការចូលរួមតស៊ូមតិ និងភាពជាអ្នកដឹកនាំ នៅសាលារៀនរបស់ពួកគាត់។🎉


















ការកែប្រែថ្មីៗ អំពីថវិកា ប្រចាំខែឧសភា

ការកែសម្រួលថវិការដ្ឋាភិបាលហ្វ៊ូវញ៉ូប្រចាំខែឧសភា របស់អភិបាលរដ្ឋ ត្រូវបានចេញផ្សាយនៅថ្ងៃទី14 ខែឧសភា ហើយនឹងជួយជូនដំណឹងដល់ការរៀបចំផែនការថវិការបស់មន្ទីរអប់រំ សម្រាប់ឆ្នាំសិក្សា 2026-27។ នៅថ្ងៃទី3 ខែមិថុនា មន្ទីរអប់រំនឹងធ្វើបទបង្ហាញអំពីផែនការគ្រប់គ្រង និងគណនេយ្យភាព ប្រចាំមូលដ្ឋាន (LCAP) ឆ្នាំ2026-27 និងសំណើថវិកាដែលបានដាក់ទៅក្រុមប្រឹក្សាភិបាលអប់រំ ដោយបញ្ចូលព័ត៌មានថ្មី ដែលឆ្លុះបញ្ចាំងនៅក្នុងការកែសម្រួលនៅខែឧសភានោះ។ បន្ទាប់ពីធ្វើបទង្ហាញនោះហើយ មន្ទីរអប់រំនឹងចែករំលែកនូវការកែប្រែថ្មីៗរបស់ថវិកា ជាមួយសហគមន៍ LBUSD និងប្រកាសផ្សាយព័ត៌មានបន្ថែមទៀត នៅលើគេហទំព័រ អំពីការកែប្រែថ្មីៗរបស់ថវិកា ក្នុងអំឡុងសប្តាហ៍ដំបូងនៃខែមិថុនា។


lbschools.net/budget.

LONG BEACH UNIFIED • SCHOOL • DISTRICT
Community Budget Update – Fall 2025

បណ្តាញចូលមើលថវិការបស់រដ្ឋាភិបាលហ្វ៊ូវញ៉ូ
California Budget Link



ផែនការគ្រប់គ្រង និងគណនេយ្យភាព ប្រចាំមូលដ្ឋាន (LCAP)




ព្រឹត្តិការណ៍ និងឱកាសចូលរួមក្នុងពេលឆាប់ៗខាងមុខនេះ

សូមពិនិត្យមើលផ្នែកនេះជារៀងរាល់ខែ សម្រាប់សិក្ខាសាលា កិច្ចប្រជុំក្រុមមាតាបិតា និងព្រឹត្តិការណ៍នានារបស់មន្ទីរអប់រំ ដែលមានក្នុងពេលឆាប់ៗខាងមុខនេះ។ សូមកុំភ្លេចចូលរួមក្នុងឱកាស ដើម្បីភ្ជាប់ទំនាក់ទំនង រៀនសូត្រ និងចូលរួមជាមួយសហគមន៍សាលារៀនរបស់យើង។

ខែឧសភា

អាទិត្យ	ច័ន្ទ	អង្គារ	ពុធ	ព្រហស្បតិ៍	សុក្រ	សៅរ៍
					1	2 ពិធីប្រារព្ធអបអរ AAPI នៅសាលា Cabrillo ម៉ោង 10:00 ព្រឹក
3	4	5 DELAC – ម៉ោង 9:30ព្រឹក EONA – ម៉ោង 5:30ល្ងាច	6	7	8	9
10	11 ភូមិមាតាបិតាសាំងកូហ្គា (SPV) ម៉ោង 5:30 ល្ងាច	12 កិច្ចប្រជុំពិសេសរបស់ក្រុមប្រឹក្សាភិបាលអប់រំ ម៉ោង 5:00 ល្ងាច	13	14 DCAC នៅវិទ្យាល័យ Browning ម៉ោង 5:30–6:30 ល្ងាច	15	16 Robo Bowl ម៉ោង 8:00 ព្រឹក
17	18 កិច្ចប្រជុំពិសេសរបស់ក្រុមប្រឹក្សាភិបាលអប់រំ ម៉ោង 1:30 រសៀល កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាភិបាលអប់រំ ម៉ោង 5:00 ល្ងាច	19	20 CAC នៅវិទ្យាល័យ Browning ម៉ោង 6:00 ល្ងាច	21	22	23
24 / 31 ពិធីទទួលសញ្ញាបត្រសិស្សអាមេរិកខ្មៅ នៅវិទ្យាល័យ Jordan ម៉ោង 4:00 ល្ងាច	25	26	27	28	29 C.A.F.E. ម៉ោង 9:30 ព្រឹក	30

មហាវិទ្យាល័យមាតាបិតា (PU)



C.A.F.E.



DCAC



EONA



DELAC

